នគរ មាន សេដ្ឋី



នគរ មាន សេដ្ឋី

នគរ មាន សេដ្ឋី មាន ភូមិគ្រិះ ធើតឆាយ មាន រថយន្ត ទំនើប មាន ភោជនីយដ្ឋាន អាហារសិល្ប: មាន ភណ្ឌាគារ លក់ ទំនិញ ប្រណិត មាន រោងចក្រ បរទេស មិនអាច ចាត់ទុក ថា ជា នគរ មាន ការរីកចំរើន បានៃនោះឡើយ បើ ហាន:ជីវភាព របស់ ប្រជាពលរដ្ឋ មាន ហាន: ទាប[1] ព្រោះ មាសិកជន[2] មាន ប្រាក់ ចំណូលរបស់បុគ្គល[3] ប្រចាំ ថ្ងៃ មាន កំរិត មិនសមរម្ម ដែល មិនអាច ឲ ជីវភាពខ្លួន មាន ការរស់នៅ សមស្រប ជា មនុស្ស មាន ភាពធូរស្រាល។

ករណី ស្រុកខ្មែរ សព្វថ្ងៃ គឺ ជា នគរ មាន ភាពមិនប្រក្រតី នៃ ការគ្រប់គ្រងជាតិ ជា ច្រើន ទាំងវិស័យ នយោបាយ, សង្គមកិច្ច និង សេដ្ឋកិច្ច ដែលបណ្ដាលឲ ស្រុកខ្មែរ ស្ថិត នៅ ក្នុង ចំណាត់ ថ្នាក់ ជា ប្រទេស គ្មាន ការរីកចម្រើន ពិតប្រាកដ ឬ ជា ប្រទេស ក្រ នៅ ក្នុង ពិភពលោក និង នៅ ក្នុង ដំបន់ អាស៊ី។ ភាពមិនប្រក្រតី នេះឯង ដែល អនុគ្រោះ ឲមាន ការកើន នៃ

---

[1] កំរិត ទលិទ្ធភាព (seuil de pauvreté) ក្នុង ពិភពលោក សព្វថ្ងៃ គឺ គេ កំ រិត ប្រាក់ ចំណូល ១,៩ ដុល្លារ ក្នុង មួយ ថ្ងៃ គឺ ថា ៥៧ ដុល្លារ ក្នុង មួយ ខែ។

[2] មាសិកជន; travailleur mensualisé។

[3] ប្រាក់ចំណូលរបស់បុគ្គល; revenu individuel។

នគរ មាន សេដ្ឋី

អំពើពុករលួយ និង គ្មាន សីលធម៌ នៅ ក្នុង ជួរ អ្នកដឹកនាំ មួយក្តាប់ ក្លាយទៅជា អ្នកមានទ្រព្យសម្បត្តិ មហាសាល និង ជាទូទៅ ក្លាយ ជា មន្ត្រី ស៊ីសំណូក លើ សេចក្តីវិនាស របស់ ប្រជាពលរដ្ឋ រស់ ក្នុង ភាពក្រីក្រគោកយ៉ាក។ ឧទហរណ៍ គណបក្ស កាន់អំណាច គេ មាន លុយរាប់សែន ដុល្លារ សំរាប់ ធ្វើបុណ្យសព លោក សុខ អាន ចំណែកឯ ខ្មែរ អ្នកក្រ ស្ទើរ តែ គ្មានលុយ សំរាប់ ទិញ ក្តារមួ្ឍស ដាក់ សព មាតា បីតា ឬ ញាតិ ដែល បាន ទទួល អនិច្ចកម្ម។ នៅក្នុង ប្រព័ន្ធ ដឹកនាំ ពុករលួយ ដោយ ឥតមន្ទិល (sans doute) ពួក អ្នកដឹងនាំ ជ្រើនជាមនុស្ស អត្តានិយម ហើយមាន លក្ខណៈ ជ្រុលនិយម ទៅជា ជនផ្តាច់ការ ក្រាប់ក្រងដឹកនាំប្រទេស ដោយ ប្រើ អំណាចរដ្ឋ ដើម្បី រក្សាតែ ទ្រព្យសម្បត្តិ មហាសាល និង បុព្វសិទ្ធិ របស់ខ្លួន។ ពួក មន្ត្រី ស៊ីសំណូក ជា មួយនឹង ពួក ឧកញ៉ា ពូកែ សូក រួមគ្នា បង្កើត ជា បណ្តាញ ក្រុមចោរ ឬ រណ្ណ អភិជន រណ្ណ គហបតី សំរាប់ លួចជាតិ បំផ្លាញជាតិ តាមសេរី។ ពួក ទាំងនោះ មាន លុយ ខុសច្បាប់ ចាយ សប្បាយ ហ៊ីហា ឥតខ្ជាស រាស្ត្រ ក្រីក្រ ហើយ ផុង ចូលក្នុង រ៉ាប្ជ ធ្ម ពាលា ក៏ ឆ្ងួតស្រី ឆ្ងួតស្រា ឆ្ងួតល្បែងពាលាអារ៉ាស៊ែ ជា ពិសេស ឆ្ងួត ខ្លាច ឃ្លួន។ ពួក ជនពាល ទាំងនោះ មាន ចំនួន ប្រមាណ ១% នៃ ចំនួន ប្រជាជនខ្មែរ រស់នៅ ក្នុង នគរ មាន លក្ខណៈ សិប្បនិម្មិត ជា នគរ មាន សេដ្ឋី តែ គ្មាន សីលធម៌ បំពុល ប្រព័ន្ធតុលាការ និង បំផ្លាញ ប្រជាជាតិខ្មែរ។

ជាតិងាប់ក៏ងាប់ទៅ ឲតែខ្លួនរស់ស្រួល ជា សេដ្ឋី.